# ប្រវត្តិ
# "ពុទ្ធិកសមាគមកម្ពុជរដ្ឋ"

## ប្រវត្តិ
## "ពុទ្ធិកសមាគមកម្ពុជរដ្ឋ"

**ពុទ្ធិកសមាគមកម្ពុជរដ្ឋ** សរសេរកាត់ថា (ព.ស.ក )ជាសមាគមមនុស្សធម៌ក្រៅរដ្ឋាភិបាលមួយមុនគេ មិនស្វែងរកកម្រៃ មិនបម្រើនិន្នាការនយោបាយ គណបក្ស មិនលំអៀងទៅខាងគណៈសង្ឃណាមួយ ត្រូវបានបង្កើត ឡើងក្នុងឆ្នាំ១៩៥២ មកម្ល៉េះ តាមព្រះរាជយោបល់ផ្តួចផ្តើមរបស់ **សម្តេចព្រះមហាសុមេធាធិបតី ជួន ណាត (ជោតញ្ញាណោ)** កាលនោះនៅជាព្រះសង្ឃនាយកនៃគណៈមហានិកាយ ក្រោមព្រះរាជឧបត្ថម្ភនៃ ព្រះមហាក្សត្រជាទីសក្ការៈ និង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឧត្តមប្រយោជន៏របស់សង្គមជាតិ និងព្រះពុទ្ធសាសនារបស់រដ្ឋ ព្រមទាំងដើម្បីភ្ជាប់ទំនាក់ទំនងជាមួយពុទ្ធសាសនា ដែលតាងដោយអង្គការពិភពលោកមួយឈ្មោះ "**ពុទ្ធិកសមាគមពិភពលោក** " (The World Fellowship of Buddhists) សរសេរកាត់ថា WFB ឬ (ព.ស.ព)។

បុព្វហេតុដែលនាំឱ្យបង្កើតពុទ្ធិកសមាគមកម្ពុជរដ្ឋឡើង បានផ្តើមពីព្រឹត្តិការណ៏ដូចតទៅ:

នៅក្នុងឆ្នាំ១៩៥0 មានលិខិតអញ្ជើញមួយផ្ញើមកពីប្រទេសស្រីលង្កា សុំនិមន្តអញ្ជើញគណៈប្រតិភូពុទ្ធ សាសនាកម្ពុជា ទៅចូលរួមប្រជុំក្នុងសន្និសីទពុទ្ធសាសនាពិភពលោក (A World Buddhists conference) ដែលត្រូវប្រព្រឹត្តទៅពីថ្ងៃទី២៦ ខែឧសភា ដល់ថ្ងៃទី៦ ខែមិថុនា ឆ្នាំ១៩៥0 នៅទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា ដើម្បីបង្កើត"ពុទ្ធិកសមាគមពិភពលោក "។ នៅក្នុងការប្រជុំនេះ មានប្រតិភូ១២៩រូប ជាសង្ឃ និងគ្រហស្ថមក ពីប្រទេសទាំង២៧នៅអាស៊ី អ៊ឺរ៉ុប អាមេរិកខាងជើង (រួមមាន ហាវ៉ៃផង)បានចូលរួមដោយមានតំណាងនិកាយពុទ្ធសាសនាផ្សេងៗគ្នាមានជាអាទិ៍មហាយាន ថេរវាទ និងវជ្រយាន។

គោលបំណងនៃការប្រជុំនេះគឺ ដើម្បីបង្កើតឡើងនូវសមាគមពុទ្ធសាសនាពិភពលោកមួយ ដោយផ្អែកលើមូលហេតុចម្បងថា ប្រជាជនពិភពលោកប្រមាណ១/៥ ជាអ្នកជឿ និងប្រតិបត្តិតាមពុទ្ធសាសនា។ ភាគច្រើននៃប្រជាពុទ្ធសាសនិកទាំងនោះបានរស់ក្នុងបណ្តាប្រទេសដូចជាស្រីលង្កា ថៃឡង់ដ៏ កម្ពុជា ឡាវ វៀតណាម កូរ៉េ ជប៉ុន និងទីបេត៏ ហើយក៏មាននៅក្នុងប្រទេសផ្សេងទៀតដូចជាចិន ឥណ្ឌា ម៉ុងហ្គោលីផងដែរ។

ក្នុងអំឡុងពីរ ឬ បីសតវត្សកន្លងទៅ ការជាប់ចិត្តក្នុងពុទ្ធសាសនា ត្រូវបានសង្កេតឃើញមាននៅបណ្តាប្រទេសលោកខាងលិចជាច្រើនផងដែរ ហើយក៏មានសមាគមធំៗបង្កួរនៅក្នុងប្រទេសអាមេរិក អង់គ្លេស បារាំង អាឡឺម៉ង់ និងក្នុងបណ្តាប្រទេសអឺរ៉ុបផ្សេងទៀត ។

ប្រទេសជាច្រើននៅអាស៊ី ដែលមានឈ្មោះរៀបរាប់ខាងលើ បានទទួលឥទ្ធិពលនិងវប្បធម៌នានាយ៉ាង ជ្រាលជ្រៅអំពីព្រះពុទ្ធសាសនា អស់ពេលរាប់ពាន់ឆ្នាំមកហើយ ដូចជា សិល្បៈ ស្ថាបត្យកម្ម ចម្លាក់ របាំ ចម្រៀង សុទ្ធតែបានទទួលឥទ្ធិពលពីសង្កប្បពុទ្ធសាសនា (Buddhist Thought) យ៉ាងទូលំទូលាយ ។

ទោះបីមានស្ថានភាពដូច្នេះក្តីក៏មិនមានការទាក់ទងគ្នាគ្រប់គ្រាន់ក្នុងចំណោមប្រជាពុទ្ធសាសនិកទាំងឡាយ នៅក្នុងប្រទេសនោះទេ ថ្វីបើប្រទេសទាំងឡាយដូចស្រីលង្កា ភូមា ថៃឡង់ដ៍ បានបញ្ជូនគណៈប្រតិភូសាសនា និងវប្បធម៌ទៅផ្លាស់ប្តូរទស្សនកិច្ចគ្នាម្តងម្កាលក្តី នៅក្នុងអំឡុងប៉ុន្មានសតវត្សខាងក្រោយនេះ ។ ក្នុងអំឡុងពេលដែលចំណងសាសនានិងវប្បធម៌រឹងមាំបានកើតមាន រវាងប្រទេសឥណ្ឌា និងដែនដីកាន់ពុទ្ធសានាទាំងអស់ គឺជាកម្លាំងរស់នៅក្នុងប្រទេសកំណើតរបស់ខ្លួន ។

ដោយហេតុតែគ្មានការផ្លាស់ប្តូរទស្សនៈរវាងគ្នានឹងគ្នា គ្មានការទាក់ទងប្រាស្រ័យគ្នាឱ្យបានសមស្រប ក្នុងចំណោមអ្នកកាន់ពុទ្ធសាសនាផ្សេងគ្នា អស់ពេលរាប់រយឆ្នាំទើបមានការបកស្រាយព្រះធម៌ បណ្តាលឱ្យកើតមានការបែងចែកជាបក្សពួក ។ អ្នកប្រតិបត្តិតាមទម្រង់ពុទ្ធសានាមហាយាន មិនសូវរាប់រកជិតស្និទ្ធ និងមិនទោរទន់មករកអ្នកប្រតិបត្តិតាមទម្រង់ពុទ្ធសាសនាថេរវាទ ហើយការប្រកាន់ឥរិយាបថនេះ មានដូចគ្នាទៅវិញទៅមក ហើយក៏គ្មានការប៉ុនប៉ងដោយភាគីណាមួយ ដើម្បីយល់ដឹងអំពីអ្នកដទៃ និងទាញយកអត្ថប្រយោជន៍អំពីមរតកវប្បធម៌របស់អ្នកដទៃទៅវិញទៅមកទេ ។

ដោយសារស្ថានភាពដូចនេះ ទោះបីពុទ្ធសាសនិកជនរួមផ្តុំគ្នាជាផ្នែកដ៏ធំនៃប្រជាជនពិភពលោកក្តីក៏ទស្សនៈរបស់ពួកគេមិនត្រូវបានគេយល់ច្បាស់ទេ ហើយបំណងប្រាថ្នារបស់ពួកគេមិនត្រូវបានគោរព និងផ្តល់កិត្តិយសទេនៅក្នុងអង្គប្រជុំធំៗរបស់ពិភពលោកឡើយ ហើយពួកពុទ្ធសាសនិកទូទាំងពិភពលោក មិនអាចដោះស្រាយភាពអយុត្តិធម៌ដែលអាជ្ញាធរអាណានិគមផ្សេងៗបានដាក់គំនាបមកលើពួកខ្លួនបានឡើយ ។

គឺស្ថិតក្នុងស្ថានភាពដូចនេះហើយ ទើបគំនិតផ្តួចផ្តើមបង្កើតអង្គការអន្តរជាតិរបស់ពុទ្ធសាសនិកទូទាំងពិភពលោកត្រូវបានចាប់បដិសន្ធិឡើង ទាំងអស់នេះគឺជាការផ្តើមដោយលោកសាស្ត្រាចារ្យល្បីឈ្មោះ **គុណបាល បិយសេនា មាឡាឡាសេកេរៈ** ។ លោកធ្លាប់បានអញ្ជើញមកប្រទេសកម្ពុជា និងបាននាំយកព្រះសារីរិកធាតុព្រះពុទ្ធបរមគ្រូ ពីស្រីលង្កា មកជូនប្រទេសកម្ពុជាកាលពីឆ្នាំ ១៩៥២ ។

ដោយប្រការយ៉ាងនេះ ពុទ្ធិកសមាគមពិភពលោក (The World Fellowship of Buddhists) ត្រូវបានស្ថាបនាឡើងនៅថ្ងៃទី២៥ ខែឧសភា ព.ស ២៤៩៣ គ.ស ១៩៥0 ក្នុងទីក្រុងកូឡុំបូ ប្រទេសស្រីលង្កា។ សម័យប្រជុំមហាសន្និបាតលើកទី១នៃពុទ្ធិកសមាគមពិភពលោក ត្រូវបានផ្តល់ជូនប្រទេសស្រីលង្កា ធ្វើជាម្ចាស់ផ្ទះក្រោមការ

ដឹកនាំរបស់លោកបណ្ឌិត គ.ប **មាឡាឡា សេកេរៈ**។ ព្រឹត្តិការណ៍ដ៏សំខាន់ និងជាសាកលនៃការសម្ពោធកំណើតពុទ្ធិកសមាគមពិភពលោកនេះ ត្រូវបានរៀបចំឡើងនៅថ្ងៃពិសាខបូជា គឺថ្ងៃទី២៥ ខែឧសភា ឆ្នាំ ១៩៥០ នៅឯវត្ត Dalada Miligawa ជាវត្តពិសិដ្ឋតម្កល់ទុកព្រះទន្តធាតុ នៃព្រះបរមគ្រូក្នុងក្រុងកាណ្ឌី ស្រីលង្កា ដោយមានប្រកាសជាឧឡារិក នូវសេចក្តីសម្រេចចិត្តដូចតទៅ:

" *យើងខ្ញុំទាំងឡាយ ដែលជួបជុំគ្នាជាអង្គប្រជុំ នៃពុទ្ធសាសនិកទាំងឡាយមកពីប្រទេស និងអង្គការជាច្រើន នៃផ្នែកទាំងអស់របស់ពិភពលោកបានមកប្រជុំនៅក្នុងបូជណីយដ្ឋាននៃព្រះវិហារពិសិដ្ឋតម្កល់ព្រះទន្តធាតុ នៅក្រុង កាណ្ឌី ជារដ្ឋធានីបុរាណរបស់ព្រះរាជាពុទ្ធសាសនិកនៃស្រីលង្កា ថ្ងៃនេះសូមប្តេជ្ញាថ្វាយខ្លួនយើងខ្ញុំ និងអ្នកទាំងឡាយដែលយើងខ្ញុំតាង ដើម្បីធ្វើការខិតខំដ៏មោះមុតបំផុតសំដៅប្រកាន់ខ្ជាប់ និងប្រតិបត្តិ តាមពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធជាអម្ចាស់ យើងខ្ញុំទាំងឡាយអាចតាំងខ្លួន ជាគំរូ ដ៏ត្រចះច្រង់នៃសទ្ធាកំពុងធរមាន ដើម្បីពង្រីង ឯកភាព សាមគ្គីភាព និងភាតរភាព ក្នុងចំណោមពុទ្ធសាសនិកទាំងឡាយគ្រប់ទិសទី ដើម្បីប្រឹងប្រែងឱ្យអស់ពីកម្លាំងកាយចិត្ត ធ្វើឱ្យលទ្ធិដ៏ប្រសើររបស់ព្រះពុទ្ធបរមគ្រូ ត្រូវបានគេយល់ដឹងសំដៅធ្វើឱ្យស្មារតីទន់ភ្លន់ និង សប្បុរស* (**Lenign Spirit**) *នៃសេវា និងពលិកម្មអាចផ្សព្វផ្សាយជ្រួតជ្រាបទូទាំងពិភពលោក អូសទាញ និងជះឥទ្ធិពលលើប្រជាជននៅលើផែនដី និងរដ្ឋាភិបាលរបស់គេឱ្យប្រកាន់យកមាគ៌ាចិញ្ចឹមជីវិតតាមពុទ្ធសាសនា ដែលសម្រាប់មនុស្សគ្រប់វិស័យ និងគ្រប់សម័យកាលសូមឱ្យមានសន្តិភាព និងសុខុដុមក្នុងចំណោមមនុស្សទាំងឡាយ និង សុភមង្គលសម្រាប់សព្វសត្វ ។ ដើម្បីសម្រេចបានបំណងនេះ យើងខ្ញុំទាំងឡាយសូមធ្វើសេចក្តីអធិដ្ឋាន ក្នុងទីនេះថា ពុទ្ធសាសនិកសមាគមពិភពលោក ត្រូវបានបង្កើតឡើងហើយ ប្រធានប្រតិភូទាំងឡាយ ដែលមានវត្តមាននៅទីនេះ ត្រូវបានផ្តល់អំណាចឱ្យដើម្បីអនុវត្តសេចក្តីសម្រេចចិត្ត និងធ្វើឱ្យសេចក្តីសម្រេចនេះ ចូលជាធរមានភ្លាម។ សូមព្រះពររបស់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃកើតមានដល់យើងខ្ញុំទាំងឡាយ និងដល់ការ ខិតខំរបស់យើងខ្ញុំទាំងឡាយ* "។

សេចក្តីសម្រេចចិត្តនេះ មានសារៈសំខាន់បំផុត ដែលពុទ្ធសាសនិកទាំងឡាយធ្វើឡើងក្នុងយុគសម័យ ក្រោយសង្គ្រាមលោកលើកទី២ ហើយមួយផ្នែកដ៏សំខាន់នៃសេចក្តីសម្រេចចិត្ត ត្រូវបានបញ្ចូលក្នុងបុព្វកថា នៃធម្មនុញ្ញពុទ្ធិកសមាគមពិភពលោក ដែលបានអនុម័តហើយកាលពីថ្ងៃទី៦ ខែ មិថុនា ឆ្នាំ ១៩៥០។

មហាសន្និបាត ពុទ្ធិកសមាគមពិភពលោកលើកទី២ ត្រូវបានកោះប្រជុំនៅទីក្រុងតូក្យូ នៅឯព្រះវិហារ (Tukiji Hingwanji) (**ត្សឹគីជី ហុងវាន់ជី**) កាលពីថ្ងៃទី២៥ ដល់ទី៣០ ខែកញ្ញា ឆ្នាំ១៩៥២។ កាលនោះ ព្រះសង្ឃនាយក **ហួត តាត** កាលនៅជាព្រះពោធិវង្ស និងជាចាងហ្វាងសាលាបាលីជាន់ខ្ពស់ បានដឹកនាំគណៈប្រតិភូពុទ្ធសាសនាកម្ពុជា ទៅចូលរួមក្នុងមហាសន្និបាតលើកទី២ នៃពុទ្ធិកសមាគមពិភពលោក។

គឺក្នុងឆ្នាំ១៩៥២នោះឯង ដែលពុទ្ធិកសមាគមកម្ពុជរដ្ឋ ត្រូវបានបង្កើតឡើង ហើយបានក្លាយទៅជា " **ពុទ្ធិកសមាគមមជ្ឈមណ្ឌលកម្ពុជរដ្ឋ** " របស់ពុទ្ធិកសមាគមពិភពលោក ដែលមានគោលបំណង និងកម្មវត្ថុដូចតទៅ:

១-ជ្រោងខ្ពស់ក្នុងចំណោមសមាជិកទាំងឡាយ នូវការប្រកាន់តាម និងការប្រតិបត្តិតាមពាក្យប្រៀន ប្រដៅរបស់ព្រះពុទ្ធ ។

២-ធានារ៉ាប់រងឯកភាព សាមគ្គីភាព និងភាតរភាព ក្នុងចំណោមពុទ្ធសាសនិកជនទាំងឡាយ

៣-ផ្សព្វផ្សាយលទ្ធិដ៏ប្រសើររបស់ព្រះពុទ្ធ

៤-រៀបចំនិងធ្វើសកម្មភាពក្នុងវិស័យបម្រើសង្គមកិច្ចអប់រំ វប្បធម៌ និងមនុស្សធម៌ទាំងឡាយដទៃទៀត

៥-ធ្វើការសម្រាប់សុភមង្គល សុខុដុមរមនា និងសន្តិភាព នៅលើផែនដី និងធ្វើសហការជាមួយ អង្គការទាំងឡាយឯទៀតដែលធ្វើការសម្រាប់គោលបំណងដូចគ្នា។

គោលបំណង និងកម្មវត្ថុរបស់ពុទ្ធិកសមាគមពិភពលោក ដូចបញ្ជាក់ខាងលើនេះមានអត្ថន័យប្រហាក់ប្រហែលគ្នានឹងគោលបំណង និងកម្មវត្ថុរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋដែរ។ ប្លែកតែត្រង់អត្ថន័យរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ សង្កត់ធ្ងន់លើបញ្ហាទាំងឡាយ ដែលជាសេចក្តីត្រូវការជាក់ស្តែងក្នុងសង្គមរបស់យើង ឧទាហរណ៍ ការផ្តោតលើការអប់រំ បណ្តុះបណ្តាលធនធានព្រះសង្ឃ សកម្មភាពប្រជាសង្គ្រោះជាដើម ។

ចាប់ពីពេលបដិសន្ធិឡើងក្នុងឆ្នាំ១៩៥២រៀងមក ពុទ្ធិកសមាគមកម្ពុជរដ្ឋបានធ្វើសកម្មភាពបម្រើសង្គមនិង សាសនារបស់រដ្ឋបានលទ្ធផលយ៉ាងល្អ។ យ៉ាងណាមិញបានជម្រុញឱ្យបង្កើតឡើង សមាគមគិលានសង្គ្រោះចំពោះ ព្រះសង្ឃ "**ព្រះកុសមៈនារីរ័ត្ន**" រហូតដល់ស្ថាបនាបាននូវមន្ទីរពេទ្យព្រះសង្ឃដែលនៅគង់វង្សសព្វថ្ងៃបានបញ្ជូនសាមណេរ និស្សិតឱ្យទៅបន្តការសិក្សា នៅប្រទេសឥណ្ឌា ស្រីលង្កា ភូមា ថៃឡង់ដ៏ជាច្រើនអង្គដោយផ្តល់ អាហារូបករណ៍ ដល់សមណនិស្សិតទាំងនោះ ធ្វើឱ្យបញ្ញវ័នសង្ឃសម្បូរ ហើយការគោរពប្រតិបត្តិពុទ្ធសាសនាបានល្អផូរផង់ បានទទួលធ្វើជាម្ចាស់ផ្ទះសម្រាប់មហាសន្និបាតលើកទី៦នៃពុទ្ធិកសាមគមពិភពលោក ក្នុងក្រុងភ្នំពេញពីថ្ងៃទី១២ដល់ទី២២ខែវិច្ឆិកាឆ្នាំ១៩៦២ដែលនៅក្នុងឱកាសនោះ ព្រះប្រមុខរដ្ឋនិងប្រមុខរដ្ឋាភិបាល **សម្តេចព្រះ នរោត្តម សីហនុ** ទ្រង់បានយាងជាព្រះរាជធិបតីប្រកាសបើកការប្រជុំមហាសន្និបាត។ សមាជិក សមាជិកា នៃអង្គមហាសន្និបាត បានចាំមិនភ្លេចនូវអនុស្សាវរីយ៍នៃការធ្វើទស្សនកិច្ចអង្គរវត្តនិងប្រាសាទនានាក្នុងខេត្តសៀមរាប។ គួរបញ្ជាក់ផងដែរថា សាលសន្និសីទចតុមុខត្រូវបានកសាងសម្រាប់ការប្រជុំមហាសន្និបាតលើកទី៦នៃពុទ្ធិកសមាគម ពិភពលោកហើយមានការជួយគាំទ្រពីក្រសួងធម្មការ ផងដែរ។ ក្នុងឱកាសដែលព្រះរាជាណាចក្រកម្ពុជាបានឈ្នះក្តី បានប្រាសាទព្រះវិហារមកវិញនៅថ្ងៃអាទិត្យ ៧រោជ ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥០៥ ត្រូវនឹងថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ១៩៦២ នៅល្ងាចថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៦២នៅវេលាម៉ោង១៩ មានការជួបជុំសមាជិក សមាជិកា ពុទ្ធិកសមាគមកម្ពុជរដ្ឋ និងពុទ្ធបរិស័ទ នៅរាជធានីភ្នំពេញ ប្រារព្ធនៅវត្តឧណ្ណាលោម ។ ព្រះភិក្ខុសង្ឃទាំងពីរគណៈ និងគ្រប់ឋានានុក្រមចំនួន៣០អង្គចម្រើនព្រះបរិត្ត ក្រោមអធិបតីភាពនៃសម្តេចព្រះមហាសុមេធាធិបតី។

ថ្ងៃច័ន្ទ ៨រោជ ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥០៥ (២៥-០៦-៦២) ម៉ោង៨:០០ ជួបជុំសមាជិកពុទ្ធិកសមាគមកម្ពុជរដ្ឋនិងពុទ្ធ បរិស័ទម៉ោង៩:០០ និងធ្វើ

ពិធីរាប់បាត្រព្រះសង្ឃប្រហែល៥០០អង្គ។ មុនពេលដែលពុទ្ធបរិស័ទដាក់បាត្រព្រះសង្ឃ ស្វាធ្យាយធម៌ពាហុំ និងមង្គលសូត្រដរាបចប់ហើយដាក់បាត្រតទៅ។

ចាប់ពីពេលត្រូវបានបង្កើតឡើង ពុទ្ធិកសមាគមកម្ពុជរដ្ឋ បានបម្រើគោលបំណងនិងកម្មវត្ថុដែលមានចែង ក្នុងលក្ខន្តិកៈរបស់ខ្លួន ប្រកបដោយជោគជ័យរហូតដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ទើបមានរដ្ឋប្រហារទម្លាក់ **សម្តេចព្រះ នរោត្តម សីហនុ** ពីតំណែងប្រមុខរដ្ឋ។ ក្រោយមក មានឯកឧត្តម វ៉ាយ ប៊ុក ជាប្រធានដឹកនាំពុទ្ធិកសមាគមកម្ពុជរដ្ឋ (មិនទាន់រកឃើញឯកសារបញ្ជាក់អ្នកដឹកនាំបន្តឱ្យច្បាស់ទេ)។ នៅអណត្តិចុងក្រោយ មុនរដ្ឋប្រហារមាន លោកជំទាវ **ណៃ ទាឡង់តាំង** សន្និបាតជ្រើសតាំងជាប្រធានពុទ្ធិកសមាគមកម្ពុជរដ្ឋ និងមាន លោកជំទាវ ឧកញ៉ាជាច្រើនទៀតចូលរួមបានជួយកសាងសង្គមជាតិ និងសាសនាជាច្រើន។

ក្រោយពេលប្រកាសរបបសាធារណរដ្ឋខ្មែរ ត្រូវបានប្រកាសនិងគ្រប់គ្រងប្រទេសហើយពុទ្ធិកសមាគមកម្ពុជរដ្ឋក៏ប្តូរឈ្មោះមកជា "**ពុទ្ធិកសមាគមសាធារណរដ្ឋខ្មែរ** " (ព.ស.ស.ខ) (The Buddhist Association Khmer Republic ) ជាឈ្មោះដែលមានជាប់ក្នុងបញ្ជីរបស់ពុទ្ធិកសមាគមពិភពលោក សព្វថ្ងៃនៅទីស្នាក់ការធំក្នុងទីក្រុងបាងកក ប្រទេសថៃ។ អាយុកាលដ៏ខ្លីរបស់ "**ពុទ្ធិកសមាគមសាធារណរដ្ឋខ្មែរ** " ដែលដឹកនាំដោយលោក **ប៊ុណ្ណា ចាន់ម៉ុល** ជាប្រធានដឹកនាំរហូតដល់ថ្ងៃទី១៧មេសា ឆ្នាំ ១៩៧៥ ពុទ្ធិកសមាគមកម្ពុជរដ្ឋត្រូវបាត់រូបរាងទៅវិញ។

ដោយនឹកស្តាយដល់ស្នាព្រះហស្តរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ** ដែល ជាអ្នកមានឧបការគុណយ៉ាងច្រើន ចំពោះជាតិមាតុភូមិ និងព្រះពុទ្ធសាសនារបស់រដ្ឋ ព្រមទាំងស្តាយតម្លៃគតិ បណ្ឌិតរបស់បុព្វបុរសយើង ដែលបានបម្រើឧត្តមគតិរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ (ព.ស.ក) បានលទ្ធផលត្រចះត្រចង់ជូនជាតិ និងព្រះពុទ្ធសាសនា ហើយបន្ទាប់មកមានព្រះសង្ឃ និងពុទ្ធសាសនិកជនមួយក្រុមបានស្ម័គ្រព្រះទ័យ និងស្រុះស្រួលចិត្តមូលមតិគ្នាជាឯកច្ឆ័ន្ទ ស្តារនិងពង្រីកនូវឧត្តមគតិនេះឡើងវិញ ដោយរៀបចំលក្ខន្តិកៈជាថ្មីសម្រាប់ ជាឯកសារគោលរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ (ព.ស.ក) និង សម្រេចបង្កើតពុទ្ធិកសមាគមនេះសារជាថ្មីឡើង វិញនៅឆ្នាំ១៩៩៤ ក្រោមការដឹកនាំរបស់គណៈកម្មាធិការនាយកបណ្តោះអាសន្នមួយ ដែលមាន **ឯកឧត្តម ចាន់ វ៉ែន** ជាប្រធាន។ ដំណើរការសកម្មភាពកន្លងមក គឺរៀបចំលក្ខន្តិកៈថ្មី ហើយចាត់តាំងគណៈកម្មាធិការនាយកបណ្តោះអាសន្នមួយ ដើម្បីពង្រឹងកសាងគ្រឹះពុទ្ធិកសមាគមកម្ពុជរដ្ឋ ទាំងខាងមូលដ្ឋានគតិយុត្តិ ទាំងខាងមូលដ្ឋានសម្ភារៈនិងហិរញ្ញវត្ថុ។

ពីពាក់កណ្តាលឆ្នាំ ១៩៩៤ រហូតដល់ថ្ងៃទី៤ ខែមេសា ឆ្នាំ២០០១ គណៈកម្មាធិការនាយកបណ្តោះអាសន្ន បានសម្រេចរៀបចំមហាសន្និបាតលើកទី១របស់ពុទ្ធិកសមាគមកម្ពុជរដ្ឋដើម្បីជ្រើសតាំង គណៈកម្មាធិការនាយកពេញសិទ្ធិរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋសម្រាប់អាណត្តិ២ឆ្នាំលើកទី១។ មហាសន្និបាតពុទ្ធិកសមាគមកម្ពុជរដ្ឋលើកទី១បានជ្រើសរើសបេក្ខជន បេក្ខនារី ចំនួន១៣រូប សម្រាប់គណៈកម្មាធិការនាយកពុទ្ធិក

សមាគមកម្ពុជរដ្ឋ អាណត្តិទី១ ហើយ **ឯកឧត្តម ចាន់ វ៉ែន** ត្រូវបានប្រគល់ភារកិច្ចជាប្រធានដឹកនាំ ដើម្បីពង្រីកកម្លាំងចូលរួមទូលំទូលាយក្នុងទូទាំងប្រទេសដោយបានការជួយគាំទ្រ និងឧបត្ថម្ភតាមលទ្ធភាពអំពីក្រសួងធម្មការនិងសាសនា សំដៅពង្រឹងសមាគមផ្នែកមូលដ្ឋានសម្ភារៈ ថវិកា និងសមត្ថភាព ហើយនិងផ្នែកសកម្មភាពផ្សព្វផ្សាយព្រះធម៌ អប់រំ វប្បធម៌ និងប្រជាសង្គ្រោះឆ្ពោះទៅភ្ជាប់ខ្លួនជាមួយពុទ្ធិកសមាគមពិភពលោក (The World fellowship of Buddhist) ជាថ្មីដូចសម័យអតីតកាលឡើងវិញ។

នៅដំណាច់ឆ្នាំ១៩៩៤ ពុទ្ធិកសមាគមកម្ពុជរដ្ឋ បានទទួលសេចក្តីប្រោសប្រណីដ៏ខ្ពង់ខ្ពស់បំផុតអំពី **ព្រះករុណាថ្លៃវិសេសជាអម្ចាស់ជីវិតតម្កល់លើត្បូង** និង **សម្តេចព្រះរាជអគ្គមហេសី** ជាព្រះប្រធានកិត្តិយស របស់សមាគម ហើយនៅក្នុងឆ្នាំ១៩៩៥ សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា **សម្តេច ហេង សំរិន** ប្រធានសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា **សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** កាលនោះជានាយករដ្ឋមន្ត្រីទី១ និង **សម្តេច ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក៏ទ្រង់ព្រះមេត្តា និងមេត្តាផ្តល់សេចក្តីអនុគ្រោះទទួលជាសមាជិកកិត្តិយសរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋផងដែរ។

មហាសន្និបាតពុទ្ធិកសមាគមកម្ពុជរដ្ឋលើកទី២ ត្រូវបានរៀបចំឡើង កាលពីថ្ងៃទី១០ខែមេសា ឆ្នាំ២០០៨ ដើម្បីជ្រើសតាំងគណៈកម្មាធិការនាយក ដែលមាន**ឧកញ៉ា មហាឧបាសិកា ញ៉ឹក ប៊ុនឆា** ជាប្រធាន គណៈកម្មាធិការនាយកនៃពុទ្ធិកសមាគមកម្ពុជរដ្ឋ ដោយមានទីប្រឹក្សាមន្ត្រីសង្ឃទាំងពីគណៈ វរជន ឥស្សរជន និង បញ្ញវ័នជាច្រើនរូប បានបំពេញបេសកកម្មតាមគន្លងប្រពៃណីនៃបុព្វការីរបស់ខ្លួន ដើម្បីរួមចំណែកអភិវឌ្ឍ ព្រះពុទ្ធសានារបស់រដ្ឋ និងសង្គមជាតិដោយជ្រោងខ្ពស់តួនាទីពុទ្ធសាសនា ក្នុងការអប់រំនិងប្រៀនប្រដៅសីលធម៌ ទប់ស្កាត់ការរើសអើង និងការបែងចែកបក្សពួកក្នុងសង្គមដែលបណ្តាលមកពីការប្រកាន់ជំនឿសាសនានិកាយខុសៗគ្នា ឬសាសនាផ្សេងគ្នាស្របតាមគោលនយោបាយនិងវប្បធម៌សន្តិភាព សុខុដុមភាពសាសនា ដែលរាជរដ្ឋាភិបាលកំពុងអនុវត្តសព្វថ្ងៃនេះ។ អស់រយៈកាល១៥ឆ្នាំ ហើយពុទ្ធិកសមាគមកម្ពុជរដ្ឋមិនទាន់បានស្តារនូវកិត្យានុភាពពីអតីតកាលដែលបាត់បង់ទៅហើយឱ្យមានពន្លឺចែងចាំងដូចដើមវិញទេ ។ ពុទ្ធិកសមាគមកម្ពុជរដ្ឋ ដែលបដិសន្ធិ ឡើងទុកជាស្នាព្រះហស្តរបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត** ដែលធ្លាប់មានប្រវត្តិរុងរឿង មាន ឧបការគុណចំពោះជាតិ និង សាសនានុះ កំពុងធ្លាក់ខ្លួនក្នុងអន្លង់អកុសល ដោយត្រូវបានអ្នកខ្លះចាត់ទុកថាជា **សមាគមរាយរង** បង្កើតឡើងសម្រាប់រកលុយចិញ្ចឹមក្រពះដូច្នោះ ហើយអ្នកខ្លះមើលស្រាលថាពុំមានសារៈសំខាន់ក្នុងការរួមចំណែកជួយសង្គម ខ្លះមានការ រើសអើង។

ដោយមើលឃើញអន្តការភាព គ្របដណ្តប់បាំងបិទពន្លឺចែងចាំងរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ យើងខ្ញុំទាំងឡាយក្នុងនាមគណៈកម្មាធិការនាយក ក៏ដូចជាសមាជិកសមាជិកាទាំងអស់ ទាំងព្រះសង្ឃ ទាំងពុទ្ធបរិស័ទជា គ្រហស្ថសូមអំពាវនាវដល់សម្តេច

ឯកឧត្តម លោកអ្នកឧកញ៉ា អ្នកឧកញ៉ា ឧកញ៉ា លោកជំទាវ លោកគ្រូ អ្នកគ្រូ លោកលោកស្រី សិស្ស និស្សិត បញ្ញវ័ន ព្រមទាំងប្រជាពលរដ្ឋប្រុសស្រី ជាពុទ្ធសាសនិកទូទាំងប្រទេស មេត្តាចូលរួមឧបត្ថម្ភគាំទ្រ ពុទ្ធិកសមាគមកម្ពុជរដ្ឋ តាមគ្រប់រូបភាពដូចជាចូលរួមជាសមាជិកប្រភេទផ្សេងៗដូចមានចែងក្នុងលក្ខន្តិកៈ ចូលរួមផ្តល់ជាកម្លាំងសម្ភារៈកម្លាំងចិត្តរួមសម្រួលដំណើរប្រព្រឹត្តទៅនៃសកម្មភាពនានា របស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ទុករាល់សកម្មភាពរបស់ពុទ្ធិកសមាគមកម្ពុជរដ្ឋ ជាសេវាបម្រើសង្គម បម្រើផលប្រយោជន៍ប្រជាពលរដ្ឋ និងអត្ថប្រយោជន៍ពុទ្ធសាសនារបស់រដ្ឋយើង ។

គណៈកម្មាធិការនាយកមានជំនឿថា បើមានការឧបត្ថម្ភគាំទ្រ និង ការចូលរួមរបស់កម្លាំងដូចខាងលើ នោះមានន័យថាវាជាលក្ខណៈសម្បត្តិដ៏ធំធេង ដែលមិនអាចខ្វះបានដើម្បីជួយជម្រុញឱ្យពុទ្ធិកសមាគមកម្ពុជរដ្ឋ មានឋានៈសមស្របដើម្បីទទួលបានជាសមាជិកភាពមជ្ឈមណ្ឌលភូមិភាគកម្ពុជា របស់ពុទ្ធិកសមាគមពិភពលោកដោយជោគជ័យ ។ ពុទ្ធិកសមាគមកម្ពុជរដ្ឋ ជាសមាគមជាតិតែមួយគត់ ដែលមិនរកកម្រៃអ្វីធ្វើការដោយស្ម័គ្រចិត្ត លះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីបម្រើសង្គមជាតិ និងពុទ្ធសាសនារបស់រដ្ឋ!!!

សេចក្តីរាយការណ៍ដូចបានគោរពជម្រាបជូនដូចខាងលើ គឺជាសេចក្តីសង្ខេបអំពីសកម្មភាពព្រះពុទ្ធសាសនា នៅក្នុងប្រទេសកម្ពុជា និងការវិវត្តន៏ក្នុងដំណាក់អន្តរកាលមួយដែលទាមទារការផ្តល់ការគាំទ្រ និងឧបត្ថម្ភអំពីឥស្សរជនជាន់ខ្ពស់ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាលក្នុងន័យជួយពង្រឹង និងកសាងឥទ្ធិពលជាវិជ្ជមានរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអាណត្តិថ្មីនេះ ។

ធ្វើនៅរាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៩

**គណៈកម្មាធិការនាយកពុទ្ធិកសមាគមកម្ពុជរដ្ឋ**